កំណើតទំនិញនោះទៅប្រទេសនាំចូល ដោយមិនមានការឆ្លងកាត់ប្រទេសដទៃ ក្រៅពីប្រទេសដើមកំណើតទំនិញ និងប្រទេសគម្យដ្ឋាន លើកលែងតែការឆ្លងកាត់នេះត្រូវបានធ្វើដោយសារលក្ខណៈភូមិសាស្ត្រ ឬ ចលនូបត្ថម្ភ ហើយទំនិញទាំងនោះមិនស្ថិតនៅក្នុងពាណិជ្ជកម្ម ឬការប្រើប្រាស់ និងមិនត្រូវរងនូវប្រតិបត្តិការណាមួយក្រៅពីការលើកដាក់ ឬ ប្រតិបត្តិការដើម្បីថែរក្សាទំនិញទាំងនោះឱ្យបានប្រសើរនៅប្រទេសដែលបានឆ្លងកាត់នោះ ។

- **បុគ្គល** គឺជារូបវន្តបុគ្គល ឬ នីតិបុគ្គល ។

## ជំពូកទី ២

## ការនាំចូល និងការនាំចេញ

### ផ្នែកទី ១

### ការនាំចូល

**មាត្រា ១០.-**

ទំនិញនាំចូលទាំងអស់ត្រូវបានរាយការណ៍នៅការិយាល័យគយ ឬ ទីកន្លែងផ្សេងទៀតទៅតាមការកំណត់របស់នាយកទីចាត់ការគយ និងរដ្ឋាករ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវចេញប្រកាសកំណត់ពេលវេលា របៀបរបប តម្រូវការ ឯកសារ កាលៈទេសៈ និងការលើកលែងនានាពាក់ព័ន្ធនឹងការរាយការណ៍ពីទំនិញនាំចូល ។

**មាត្រា ១១.-**

ទំនិញនាំចូលទាំងអស់ត្រូវបានរាយការណ៍នៅការិយាល័យគយដែលជិតបំផុតតាមតម្រោយផ្លូវស្របច្បាប់ :

ក-ក្នុងករណីទំនិញដែលកាន់រក្សាដោយជនណាម្នាក់ ដែលបានមកដល់កម្ពុជា ឬ ជាផ្នែកនៃអីវ៉ាន់ផ្ទាល់ខ្លួន ត្រូវរាយការណ៍ដោយជននោះ ។

ខ-ក្នុងករណីទំនិញ ដែលបាននាំចូលដោយសេវាកម្មបញ្ញើ ឬ តាមរយៈបញ្ញើប្រៃសណីយ៍ត្រូវរាយការណ៍ដោយបុគ្គលដែលបាននាំចេញទំនិញនោះមកកម្ពុជា ។

គ-ក្នុងករណីទំនិញដែលនាំចូលផ្សេងពីវាក្យខណ្ឌ ក និងវាក្យខណ្ឌ ខ ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ដែលបានផ្ទុកនៅលើមធ្យោបាយដឹកជញ្ជូនរាប់បញ្ចូលទាំងមធ្យោបាយដឹកជញ្ជូនយោធាដែលមកដល់កម្ពុជា ត្រូវរាយការណ៍ដោយជនទទួលខុសត្រូវមធ្យោបាយដឹកជញ្ជូនទាំងនោះ ។

ឃ- ក្នុងករណីទំនិញដែលនាំចូលតាមបែបផ្សេងទៀតត្រូវរាយការណ៍ដោយបុគ្គលដែលធ្វើក្នុងនាមអ្នកនាំចូល ។

បុគ្គលគ្រប់រូបដែលរាយការណ៍ពីទំនិញ ក្រោមបញ្ញត្តិនៃមាត្រានេះត្រូវ :

ក-ឆ្លើយនូវការពិត ចំពោះរាល់សំណួរដែលសួរដោយមន្ត្រីគយពាក់ព័ន្ធនឹងទំនិញរបស់ខ្លួន ។

ខ- បង្ហាញនូវទំនិញទាំងឡាយ តាមរបៀបដែលកំណត់ដោយនាយកទីចាត់ការគយ និងរដ្ឋាករសម្រាប់ធ្វើអធិការកិច្ចនៅពេលដែលមន្ត្រីគយតម្រូវ ។

**មាត្រា ១២.-**

គ្មានជនណាម្នាក់អាចរើទំនិញចេញពីមធ្យោបាយដឹកជញ្ជូនពេលមកដល់កម្ពុជាបានទេ មុនពេលដែលទំនិញទាំងនេះ ត្រូវបានរាយការណ៍ដល់គយស្របតាមច្បាប់នេះ លើកលែងតែក្នុងករណីដែលសុវត្ថិភាពមធ្យោបាយដឹកជញ្ជូនទំនិញ ជននានាលើមធ្យោបាយដឹកជញ្ជូន ឬ តតិយជនផ្សេងទៀតត្រូវបានគំរាមកំហែងក្នុងល័ក្ខខ័ណ្ឌមានអាសន្ន ដូចមានចែងក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៣.-**

រដ្ឋបាលគយអាចអនុញ្ញាតឱ្យទំនិញដូចមានចែងក្នុងមាត្រា ១០ នៃច្បាប់នេះយកចេញបានពីកន្លែងបំពេញបែបបទបញ្ចេញទំនិញពីគយ មុនពេលបង់ពន្ធ អាករ និងកម្រៃនានាបន្ទាប់ពីបានបំពេញទម្រង់ការគយរួច និងនៅក្រោមការត្រួតពិនិត្យគយក្នុងគោលបំណង :

-ធ្វើសន្និធិគយបណ្ដោះអាសន្ន

-ធ្វើសន្និធិគយមានដែនកំណត់

-ដឹកជញ្ជូនបន្តក្នុងរង្វង់ ឬ កាត់តាមដែនគយ ឆ្លោះទៅគម្យដ្ឋានមួយតាមតម្រាយផ្លូវស្របច្បាប់ និងក្នុងរយៈពេលកំណត់ដោយគយរួមមាន ការឆ្លងកាត់ ការផ្ទេរមធ្យោបាយដឹកជញ្ជូន ឬ ការដឹកជញ្ជូនឆ្ពោះទៅកាន់មកពី ឬ រវាងការិយាល័យគយ និងភណ្ឌាគារគយនានា ។

**មាត្រា ១៤.-**

ទំនិញដូចមានចែងក្នុងមាត្រា ១០ នៃច្បាប់នេះ អាចត្រូវបានអនុញ្ញាតដោយរដ្ឋបាលគយឱ្យយកចេញ បន្ទាប់ពីបានបំពេញទម្រង់ការគយរួច ដោយរាប់បញ្ចូលទាំងការបង់ពន្ធអាករ ឬ កម្រៃផ្សេងៗ និងការតម្កល់និមុត្តិធានាចំពោះទំនិញដើម្បី :

-នាំចូលសម្រាប់ការប្រើប្រាស់ក្នុងប្រទេស

-នាំចូលបណ្តោះអាសន្ន

-ប្រើប្រាស់ក្រោមល័ក្ខខ័ណ្ឌល្បួរពន្ធ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចេញប្រកាសកំណត់ល័ក្ខខ័ណ្ឌនានាចំពោះទំនិញដែលអាចត្រូវបានអនុញ្ញាតឱ្យយកចេញ មុនពេលបង់ពន្ធ អាករ និងកម្រៃផ្សេងៗ ។

**មាត្រា ១៥.-**

ទំនិញនាំចូលទាំងឡាយ អាចទទួលបានការអនុញ្ញាតដោយរដ្ឋបាលគយឱ្យយកចេញតាមរបបប្រវេសនីកាលិកបាន ប្រសិនបើក្នុងពេលនាំចូលអាចត្រូវបានបង្ហាញថាទំនិញទាំងនោះនឹងត្រូវនាំចេញទៅវិញ ។

ទំនិញនាំចូលបណ្តោះអាសន្ន ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យគយ រហូតដល់ពេលដែលល័ក្ខខ័ណ្ឌផ្សេងៗតាមរបបប្រវេសនីកាលិកត្រូវបានបំពេញរួចរាល់ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់បញ្ញត្តិនានាសម្រាប់គ្រប់គ្រងទំនិញនាំចូលក្រោមរបបប្រវេសនីកាលិកទាំងនេះ រួមមានការកំណត់រយៈពេលកម្រៃនានា ការត្រួតពិនិត្យ និងការដាក់កម្រិតកំណត់ផ្សេងទៀត ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ក្រសួងព្រះបរមរាជវាំង





13/45

# ផ្នែកទី ២
# ការនាំចេញ

**មាត្រា ១៦.-**

ទំនិញគ្រប់ប្រភេទដែលនាំចេញត្រូវរាយការណ៍នៅការិយាល័យគយ ឬ ទីកន្លែងណាមួយតាមការកំណត់របស់នាយកទីចាត់ការគយ និងរដ្ឋាករ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់ពេលវេលា របៀបរបប តម្រូវការ ឯកសារ កាលៈទេសៈ និងការលើកលែងមួយចំនួនពាក់ព័ន្ធនឹងការរាយការណ៍ ចរាចរ សន្និធិនិងការដឹកជញ្ជូនទំនិញទាំងឡាយដែលត្រូវនាំចេញ ។

បុគ្គលគ្រប់រូបដែលរាយការណ៍ពីទំនិញ ក្រោមបញ្ញត្តិនៃមាត្រានេះ ត្រូវ :

ក-ឆ្លើយនូវការពិតចំពោះរាល់សំណួរដែលសួរដោយមន្ត្រីគយ ពាក់ព័ន្ធនឹងទំនិញរបស់ខ្លួន ។

ខ-បង្ហាញនូវទំនិញទាំងឡាយ តាមរបៀបដែលកំណត់ដោយនាយកទីចាត់ការគយ និងរដ្ឋាករ សម្រាប់ធ្វើអធិការកិច្ចនៅពេលដែលមន្ត្រីគយតម្រូវ ។

**មាត្រា ១៧.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់ល័ក្ខខ័ណ្ឌនានាដែលរដ្ឋបាលគយអាចអនុញ្ញាតឱ្យធ្វើការនាំចេញបណ្ដោះអាសន្ននូវទំនិញទៅក្រៅដែនគយដើម្បីផ្គុំសផុល បំប្លែង ឬ ទទួលពលកម្មបន្ថែម ព្រមទាំងបែបបទដែលទំនិញទាំងនោះត្រូវជាប់ពន្ធ និងអាករនាពេលនាំចូលត្រឡប់មកវិញ ។

# ជំពូកទី ៣
# ចំណាត់ថ្នាក់តាមតារាង ដើមកំណើត និង តម្លៃគិតពន្ធគយ

**មាត្រា ១៨.-**

ចំណាត់ថ្នាក់តាមតារាង ដើមកំណើត និងតម្លៃគិតពន្ធគយនៃទំនិញនាំចូលដែលបានបញ្ជាក់នៅក្នុងប្រតិវេទន៍គយ ត្រូវបានប្រកាសស្របទៅតាមវិធានដូចខាងក្រោមនេះ :



14/45